## ចំណោទ

១). សាណូនិងម៉ីម៉ីបានទៅដើរលេងនៅភ្នំពេញក្នុងខែជាមួយគ្នា។ សាណូបានត្រឡប់មកផ្ទះវិញនៅខែវិច្ឆិកា។ ឯម៉ីម៉ីត្រឡប់មកខែកក្កដានៅឆ្នាំថ្មី។

តើអ្នកណាជាអ្នកមកដល់ផ្ទះមុន?

ក. សាណូ ខ. ម៉ីម៉ី

ហើយតើមកដល់មុនឬក្រោយប៉ុន្មានខែ? ចម្លើយ [ ]

២).កូនឆ្មារបស់យ៉ាយ៉ាកើតខែមករា ចំណែកកូនឆ្មារបស់ម៉ូលីកាកើតខែវិច្ឆិកា។

តើកូនឆ្មារបស់អ្នកណាកើតមុន?

ក. ម៉ូលីកា ខ. យ៉ាយ៉ា

ហើយកើតមុនឬក្រោយប៉ុន្មានខែ? ចម្លើយ [ ]

៣).កសិដ្ឋានមួយចិញ្ចឹមទា911ក្បាល។ទាងាប់ដោយជំងឺផ្តាសាយបក្សីចំនួន 523ក្បាល ។ តើកសិដ្ឋាននោះនៅសល់ទាប៉ុន្មានក្បាល?

[ ] − [ ] = [ ]

ដូចនេះកសិដ្ឋានមួយនេះនៅសល់ទា [ ] ក្បាល ។

LIVEWORKSHEETS

៤).កសិដ្ឋានចិញ្ចឹមគោមួយកន្លែង មានគោចំនួន698ក្បាល។ ក្រោយមក គាត់បានទិញគោថែមចំនួន 769ក្បាល។ តើកសិដ្ឋាននោះមានគោទាំងអស់ប៉ុន្មាន ក្បាល?

[ ] + [ ] = [ ]

ដូចនេះកសិដ្ឋានមួយនេះមានគោទាំងអស់ចំនួន [ ] ក្បាល ។

៥). សុខនាថមានលុយ 8000រៀល។ គេចង់ទៅទិញផ្លែស្រកានាគ។ ហើយ ស្រកានាគ 1 ផ្លែ មានតម្លៃ800រៀល។ តើសុខនាថទិញបានស្រកានាគបាន ប៉ុន្មានផ្លែ?

ចម្លើយ

ដូចនេះសុខនាថទិញស្រកានាគបានចំនួនបាន [ ] ផ្លែ ។

៦). ថ្ងៃនេះអ្នកគ្រូបង្រៀនចំនួន ៥ម៉ោង ។ អ្នកគ្រូចាប់ផ្តើមបង្រៀននៅម៉ោង ១រសៀល។ តើអ្នកគ្រូនឹងបញ្ចប់ម៉ោងបង្រៀននៅម៉ោងប៉ុន្មាន?

ចម្លើយ ៖ អ្នកគ្រូនឹងបញ្ចប់ម៉ោងបង្រៀននៅម៉ោង [ ] ។

LIVEWORKSHEETS